01325389

E389/6

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 06 / 09 / 2016
ម៉ោង (Time/Heure) : 15 : 40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

ចំពោះមុខ: ចៅក្រម យ៉ា សុខន ជ.ប្រធាន
ចៅក្រម **Jean-Marc LAVERGNE**
ចៅក្រម យូ អុត្តរា
ចៅក្រម **Claudia FENZ**
ចៅក្រម ធូ មណី

កាលបរិច្ឆេទ: ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៦
ភាសាដើម: ខ្មែរ/អង់គ្លេស/បារាំង
ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

# សេចក្តីសម្រេចលើកទីបី ស្តីពីសម្បទារបស់ជនជាប់ចោទ ខៀវ សំផន ក្នុងការចូលរួមសវនាការ និង ដីកាបង្គាប់ឲ្យធ្វើតេស្តទៅលើបញ្ហាសុខភាពប្រចាំត្រីមាស

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Marie GIRAUD

**មេធាវីជនជាប់ចោទ**
សុន អរុណ
Victor KOPPE
គង់ សំអុន
Anta GUISSÉ

## ១. ប្រវត្តិនីតិវិធី

១. អនុលោមតាមវិធាន ៣២ នៃវិធានផ្ទៃក្នុង តាមគំនិតផ្តួចផ្តើមរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូង បានចាត់តាំងអ្នកជំនាញពីររូបគឺ វេជ្ជបណ្ឌិត CHAN Kin Ming និង វេជ្ជបណ្ឌិត ហួត លីនណា ("អ្នកជំនាញ") ដើម្បីពិនិត្យវាយតម្លៃជនជាប់ចោទ និង ធ្វើរបាយការណ៍ស្តីពីសម្បទារបស់គាត់ក្នុងការចូលរួមសវនាការ[1] ។ បន្ទាប់ពីបានពិនិត្យវាយតម្លៃជនជាប់ចោទទៅតាមដីកាបង្គាប់របស់អង្គជំនុំជម្រះរួចហើយ អ្នកជំនាញបានដាក់របាយការណ៍របស់ខ្លួននៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦[2]។ នៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានសាកសួរភាគីនានាថាតើភាគីចង់សួរដេញដោលអ្នកជំនាញទៅលើរបាយការណ៍ និង មតិយោបល់របស់ពួកគេនៅក្នុងសវនាការថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៦ ដែរ ឬ យ៉ាងណា[3]។ នៅថ្ងៃទី ២៧ និងថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៦ ភាគី បានឆ្លើយតបតាមរយៈអ៊ីម៉ែលថា ភាគីមិនមានសំណួរសួរដេញដោលអ្នកជំនាញទាំងនោះឡើយ។ ហេតុដូច្នេះ សវនាការស្តីពីសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការពុំមានឡើយ។

២. អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានសម្រេចចំនួនពីរលើកដោយឡែកពីគ្នាថា ខៀវ សំផន មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ[4] ។ សម្រាប់គោលបំណងនៃសេចក្តីសម្រេចនេះ អង្គ-ជំនុំជម្រះបានបង្គាប់ឱ្យអ្នកជំនាញរាយការណ៍ពីព័ត៌មានដែលអាចជួយឱ្យអង្គជំនុំជម្រះសម្រេចអំពី

---

[1] ដីកាចាត់តាំងអ្នកជំនាញដើម្បីវាយតម្លៃលើសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ ឯកសារ E389 ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១៦។

[2] របាយការណ៍របស់អ្នកជំនាញវេជ្ជសាស្ត្រ៖ នួន ជា ឯកសារ E389/3 ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦។ របាយការណ៍របស់អ្នកជំនាញវេជ្ជសាស្ត្រ៖ ខៀវ សំផន ឯកសារ E389/4 ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ ("របាយការណ៍ស្តីពី ខៀវ សំផន")។ របាយការណ៍ទាំងពីរត្រូវបានដាក់ជារបាយការណ៍សម្ងាត់បំផុត ដោយសារតែវាជាបញ្ហាឯកជនរបស់បុគ្គល។

[3] អ៊ីម៉ែលពីអង្គជំនុំជម្រះសាលាដំបូងផ្ញើជូនភាគីចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦។

[4] សេចក្តីសម្រេចលើសម្បទារបស់ជនជាប់ចោទ ខៀវ សំផន ក្នុងការចូលរួមសវនាការ ឯកសារ E301/12 ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤។ សេចក្តីសម្រេចលើកទីពីរទៅលើសម្បទារបស់ជនជាប់ចោទ ខៀវ សំផន ក្នុងការចូលរួមសវនាការ ឯកសារ E329/8 ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥ ("សេចក្តីសម្រេចលើកទីពីរស្តីពីសម្បទា")។

សម្បទារបស់ជនជាប់ចោទ អនុលោមទៅតាមលក្ខណៈវិនិច្ឆ័យដែលមានរៀបរាប់ក្នុងសាលដីកាលើបណ្ដឹងសាទុក្ខក្នុង *រឿងក្ដី Strugar*[5]។

## ២. ការពិនិត្យវាយតម្លៃរបស់អ្នកជំនាញ

៣. អ្នកជំនាញបានពិនិត្យវាយតម្លៃទៅលើ ខៀវ សំផន នៅថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៦ និង បានពិនិត្យទៅលើរបាយការណ៍វេជ្ជសាស្ត្រប្រចាំសប្ដាហ៍របស់គ្រូពេទ្យប្រចាំការនៅមន្ទីរឃុំឃាំង អ.វ.ត.ក និង មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត នៅទីក្រុងភ្នំពេញ[6]។ នៅក្នុងរបាយការណ៍ស្ដីពី ខៀវ សំផន អ្នកជំនាញបានបញ្ជាក់ថា ខៀវ សំផន ធ្លាប់មានជំងឺរ៉ាំរ៉ៃជាច្រើន និង បានចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យជាច្រើនលើក ប៉ុន្តែបានកត់សម្គាល់ថា គាត់បានជាសះស្បើយទាំងស្រុងក្រោយការសម្រាកព្យាបាលនៅមន្ទីរពេទ្យនាពេលថ្មីៗនេះ ហើយនៅក្នុងឆ្នាំ ២០១៦ គាត់មិនបានចូលសម្រាកនៅក្នុងមន្ទីរពេទ្យឡើយ[7]។ អ្នកជំនាញសង្កេតឃើញថា សម្ពាធឈាម សម្លេងបេះដូង ភាពស្លេកស្លាំង ដង្ហើម និង ចង្វាក់សាច់ដុំ មានសភាពធម្មតា[8]។

៤. នៅក្នុងកិច្ចសម្ភាសរបស់គាត់ជាមួយអ្នកជំនាញ ខៀវ សំផន បាននិយាយខ្លាំងៗជាប្រយោគជាប់ៗគ្នា និង ស្ដាប់សំណួរបានដោយមិនមានការលំបាកនោះឡើយ[9]។ គាត់អាចដើរបានដោយប្រើកៅអីរុញជាជំនួយ ហើយអាចអានបានដោយប្រើកែវពង្រីក[10]។ គាត់ស្គាល់អ្នកជំនាញ ទោះបីជាគាត់មិនចាំឈ្មោះរបស់អ្នកជំនាញក៏ដោយ[11]។

៥. អ្នកជំនាញរាយការណ៍ថា វេជ្ជបណ្ឌិតដែលព្យាបាល ខៀវ សំផន នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត បានកត់សម្គាល់ថា សុខភាពរបស់គាត់មានសភាពនឹងនរជាងមុន និង មិនមានបញ្ហា

---

[5] ដីកាចាត់តាំងអ្នកជំនាញ កថាខណ្ឌ ៦ ដែលដកស្រង់រឿងក្ដីរដ្ឋអាជ្ញា ទល់នឹង *Strugar* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY សំណុំរឿង IT-01-42-A សាលដីកា ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៨ ("រឿងក្ដី *Strugar*") កថាខណ្ឌ ៥៥។

[6] របាយការណ៍ស្ដីពី ខៀវ សំផន កថាខណ្ឌ ៣, ៥។

[7] របាយការណ៍ស្ដីពី ខៀវ សំផន កថាខណ្ឌ ៦-៩។

[8] របាយការណ៍ស្ដីពី ខៀវ សំផន កថាខណ្ឌ ១៤។

[9] របាយការណ៍ស្ដីពី ខៀវ សំផន កថាខណ្ឌ ១២-១៣។

[10] របាយការណ៍ស្ដីពី ខៀវ សំផន កថាខណ្ឌ ១១, ១៣។

[11] របាយការណ៍ស្ដីពី ខៀវ សំផន កថាខណ្ឌ ១១។

សុខភាពគួរឱ្យកត់សម្គាល់ណាមួយនោះឡើយ[12] ។ វេជ្ជបណ្ឌិតរូបនោះ បានលើកឡើងបន្ថែមថា ខៀវ សំផន នៅបន្តហាត់ប្រាណនៅពេលល្ងាច អាចដើរដោយមានជំនួយ ហើយអាចអាន និង រៀបចំឯកសារនៅក្នុងកុំព្យូទ័ររបស់គាត់[13] ។ វេជ្ជបណ្ឌិតរូបនោះបានរាយការណ៍ថា ខៀវ សំផន មិនមានបញ្ហាការចងចាំ ការផ្ដង់អារម្មណ៍ ឬ អារម្មណ៍ប្រែប្រួលនោះឡើយ[14]។

៦. អ្នកជំនាញយល់ឃើញថា ខៀវ សំផន អាចផ្ដង់អារម្មណ៍បានពេញលេញនៅក្នុងអំឡុងពេល សម្ភាសន៍រយៈពេល ៦០ នាទី មានភាពរហ័សរហួន និង បានឆ្លើយតបយ៉ាងច្បាស់លាស់ចំពោះ សំណួរដែលបានសួរគាត់[15] ។ អ្នកជំនាញ មានឃើញភ័ស្តុតាងបង្ហាញច្បាស់លាស់ថា ការចងចាំ រយៈពេលវែងរបស់ ខៀវ សំផន នៅមានភាពល្អប្រសើរ ហើយគាត់ទទួលបានពិន្ទុលំដាប់ធម្មតា ចំពោះការពិនិត្យលើស្ថានភាពផ្លូវចិត្តដោយអ្នកជំនាញ[16]។ អ្នកជំនាញ យល់ឃើញថាស្ថានភាពផ្លូវ ចិត្តរបស់ ខៀវ សំផន មានសភាពធម្មតា ហើយការចងចាំរយៈពេលខ្លី ការផ្ដង់អារម្មណ៍ និងការ ផ្ដោតអារម្មណ៍របស់គាត់ គឺល្អប្រសើរសម្រាប់អាយុរបស់គាត់[17]។ អ្នកជំនាញកត់សម្គាល់ថា ការ ធ្វើតេស្តផ្នែកបញ្ញាស្មារតីជាទៀងទាត់ក្រោមទម្រង់ជាការធ្វើតេស្តសង្ខេបផ្នែកបញ្ញាស្មារតី (AMT) ត្រូវបានធ្វើឡើងសម្រាប់ ខៀវ សំផន រៀងរាល់បីខែម្តង ហើយលទ្ធផលគ្រប់តេស្តទាំងអស់ បង្ហាញឱ្យឃើញថាបញ្ញាស្មារតីរបស់គាត់មិនមានចុះខ្សោយនោះឡើយ[18]។ អ្នកជំនាញ យល់ឃើញ ផងដែរថា ខៀវ សំផន មានសមត្ថភាពចាំបាច់នានាដែលបានកំណត់នៅក្នុង *រឿងក្ដី Strugar*[19]។

៧. អ្នកជំនាញបានសន្និដ្ឋានថា នាពេលថ្មីៗនេះ ខៀវ សំផន មិនមានបញ្ហាសុខភាពណាមួយដែល ប៉ះពាល់ដល់លទ្ធភាពរបស់គាត់ក្នុងការចូលរួមសវនាការនោះឡើយ។ ទោះជាយ៉ាងណាអ្នកជំនាញ ផ្ដល់អនុសាសន៍ឱ្យនិយាយទៅកាន់គាត់ឱ្យឮៗ ច្បាស់ៗ និង យឺតៗ និង បើកភ្លើងឱ្យភ្លឺគ្រប់គ្រាន់

---

[12] របាយការណ៍ស្ដីពី ខៀវ សំផន កថាខណ្ឌ ៩-១០, ១៦។

[13] របាយការណ៍ស្ដីពី ខៀវ សំផន កថាខណ្ឌ ៩។

[14] របាយការណ៍ស្ដីពី ខៀវ សំផន កថាខណ្ឌ ២២-២៣។

[15] របាយការណ៍ស្ដីពី ខៀវ សំផន កថាខណ្ឌ ២៤។

[16] របាយការណ៍ស្ដីពី ខៀវ សំផន កថាខណ្ឌ ២៥, ២៧។

[17] របាយការណ៍ស្ដីពី ខៀវ សំផន កថាខណ្ឌ ២៨-២៩។

[18] របាយការណ៍ស្ដីពី ខៀវ សំផន កថាខណ្ឌ ២២។

[19] របាយការណ៍ស្ដីពី ខៀវ សំផន កថាខណ្ឌ ៣០-៤១។

និង ផ្តល់កែវពង្រីកឱ្យគាត់ ប្រសិនបើគាត់ត្រូវការអានឯកសារនានា[20]។ អ្នកជំនាញយល់ឃើញថា កាលវិភាគសវនាការប្រចាំថ្ងៃ នៅពេលព្រឹក និង ពេលរសៀលនាពេលថ្មីៗនេះ មានរយៈពេល ២ ម៉ោងកន្លះ និង ពេលសម្រាកមានរយៈពេល ២ ម៉ោង មានលក្ខណៈសមស្របសម្រាប់ ខៀវ សំផន[21]។ អ្នកជំនាញយល់ឃើញផងដែរថា នាពេលថ្មីៗនេះ ខៀវ សំផន មិនមានបញ្ហាសតិ ឬ បញ្ហាស្មារតីដែលប៉ះពាល់លទ្ធភាពរបស់គាត់ក្នុងការចូលរួមសវនាការ អនុលោមទៅតាមលក្ខណៈវិនិច្ឆ័យនៅក្នុង *រឿងក្តី Strugar* នោះឡើយ[22]។

៨. អ្នកជំនាញយល់ឃើញថា ការចងចាំ និង មុខងារបញ្ញាស្មារតីរបស់ ខៀវ សំផន អាចនឹងមានការធ្លាក់ចុះខ្សោយបន្តិចម្តងៗជាបន្តទៅតាមអាយុរបស់គាត់ ហើយណែនាំឱ្យមានការពិនិត្យមុខងារបញ្ញាស្មារតីរបស់គាត់ឱ្យបានទៀតទាត់ ជាពិសេស ប្រសិនបើឃើញថាមានការធ្លាក់ចុះនៃការចងចាំ ឬ បញ្ញាស្មារតីគួរឱ្យកត់សម្គាល់នោះ[23]។ អ្នកជំនាញក៏ផ្តល់អនុសាសន៍ឱ្យមានការតាមដានលើសម្ពាធឈាម និង ទម្ងន់របស់ ខៀវ សំផន ឱ្យបានជាប់លាប់ ទោះជាយ៉ាងណា បញ្ហានេះមិនគួរប៉ះពាល់ដល់លទ្ធភាពរបស់គាត់ក្នុងការចូលរួមសវនាការនោះឡើយ[24]។

## ៣. <u>ច្បាប់ជាធរមាន</u>

៩. ដើម្បីកំណត់ថា មានសម្បទាក្នុងការចូលរួមសវនាការ ជនជាប់ចោទត្រូវមានលទ្ធភាពក្នុងការចូលរួមសវនាការប្រកបដោយអត្ថន័យ ដែលមានន័យថា គាត់អាចអនុវត្តសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និង឵ឆាប់រហ័ស នៅក្នុងកម្រិតមួយដែលគាត់អាចចូលរួមបានដោយមានប្រសិទ្ធភាព និង យល់ដឹងពីផ្នែកសំខាន់ៗនៃកិច្ចដំណើរការនីតិវិធី[25]។

---

[20] របាយការណ៍ស្តីពី ខៀវ សំផន កថាខណ្ឌ ៥ នៃផ្នែកសេចក្តីសន្និដ្ឋាន។

[21] របាយការណ៍ស្តីពី ខៀវ សំផន កថាខណ្ឌ ៤ នៃផ្នែកសេចក្តីសន្និដ្ឋាន។

[22] របាយការណ៍ស្តីពី ខៀវ សំផន កថាខណ្ឌ ៧ នៃផ្នែកសេចក្តីសន្និដ្ឋាន។

[23] របាយការណ៍ស្តីពី ខៀវ សំផន កថាខណ្ឌ ៤២។

[24] របាយការណ៍ស្តីពី ខៀវ សំផន កថាខណ្ឌ ១៩។

[25] រឿងក្តី *Strugar* កថាខណ្ឌ ៥៥។

## ៤. សំអាងហេតុ

១០. នៅក្នុងការវាយតម្លៃនេះ អង្គជំនុំជម្រះពិចារណាទៅលើកត្តាទាំងអស់ដែលពាក់ព័ន្ធរួមមានភស្តុតាងពីអ្នកជំនាញ ការសង្កេតរបស់អង្គជំនុំជម្រះផ្ទាល់ ផលប៉ះពាល់ទៅលើស្ថានភាពសុខភាព របស់ជនជាប់ចោទ លទ្ធភាពនៃវិធានការអនុវត្តជាក់ស្តែងដើម្បីជួយសម្រួលផលប៉ះពាល់នៃការចុះខ្សោយ ហើយថា ជនជាប់ចោទត្រូវបានតំណាង និង ផ្តល់ការប្រឹក្សាយោបល់ពីក្រុមមេធាវីដែលមានសមត្ថភាព។

១១. បន្ទាប់ពីបានពិនិត្យមើលទៅលើរបាយការណ៍ស្តីពី ខៀវ សំផន រួចមក អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ខៀវ សំផន នៅតែមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ហើយនាពេលថ្មីៗនេះ មិនបានទទួលរងនូវការចុះខ្សោយផ្នែកស្មារតី ឬ រាងកាយ ដែលរារាំងគាត់មិនឲ្យបន្តចូលរួមក្នុងកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២/០២ ទេ។

១២. អង្គជំនុំជម្រះនឹងបន្តសវនាការទៅតាមកាលវិភាគសវនាការដែលខ្លួនបានកែសម្រួល ដែលមានរយៈពេលសម្រាក ២ ម៉ោង នៅពេលអាហារថ្ងៃត្រង់ ដើម្បីផ្តល់ពេលសម្រាកថ្ងៃត្រង់ឲ្យបានយូរ ហើយជាទូទៅ សវនាការនឹងចាប់ផ្តើមពីម៉ោង ៩ ព្រឹក ដល់ ម៉ោង ១១:៣០ ព្រឹក និងពីម៉ោង ១:៣០ ដល់ម៉ោង ៤ រសៀល ពីថ្ងៃចន្ទ ដល់ ថ្ងៃព្រហស្បតិ៍[26]។ អង្គជំនុំជម្រះក៏នឹងបន្តចាត់វិធានការជាក់ស្តែងផ្សេងៗផងដែរ ដូចជា ការអនុញ្ញាតឲ្យជនជាប់ចោទចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីតាមរយៈប្រព័ន្ធសោតទស្សន៍ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ អនុលោមតាមវិធាន ៨១(៥) នៅក្នុងករណីចាំបាច់។ អង្គជំនុំជម្រះយល់ឃើញថា វិធានការបែបនេះនឹងជួយសម្រួលបានគ្រប់គ្រាន់ដល់ការចុះខ្សោយលើស្ថានភាពសុខភាពរបស់ ខៀវ សំផន។

១៣. ដោយពិចារណាលើអនុសាសន៍របស់អ្នកជំនាញឲ្យធ្វើការពិនិត្យមុខងារបញ្ញាស្មារតីរបស់ ខៀវ សំផន ជាទៀតទាត់នោះ អង្គជំនុំជម្រះបង្គាប់ឲ្យបន្តធ្វើតេស្តមុខងារបញ្ញាស្មារតីរបស់គាត់រៀងរាល់បីខែម្តង។ អង្គជំនុំជម្រះពិចារណាឃើញថា អ្នកជំនាញត្រូវបន្តរៀបចំការធ្វើតេស្តទាំងនេះ ហើយផ្លាស់ប្តូរតេស្តទាំងនេះ ក្នុងករណីចាំបាច់ ដើម្បីជៀសវាងកុំឲ្យប៉ះពាល់ដល់លទ្ធផលដោយសារការស៊ាំទៅនឹងតេស្តពីមុន ហើយតេស្តនេះត្រូវធ្វើឡើងដោយគ្រូពេទ្យវិជ្ជាជីវៈដែលទទួលកិច្ចសន្យាផ្តល់

[26] សេចក្តីសម្រេចលើកទីពីរ ស្តីពីសម្បទា កថាខណ្ឌ ១២ *ដកស្រង់* ប្រ. ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ២៥-២៦។

សេវាជូនមន្ទីរឃុំឃាំងនៃ អ.វ.ត.ក ("អង្គភាពពេទ្យ")[27]។ នាពេលអនាគត ក្នុងករណីសមស្រប អង្គជំនុំជម្រះនឹងចេញដីកាបង្គាប់ឱ្យអនុវត្តទៅតាមអនុសាសន៍របស់អ្នកជំនាញដើម្បីបង្កើនការតាមដានលើទម្ងន់ សម្ពាធឈាម និង ការស្នាក់នៅរបស់ ខៀវ សំផន ដើម្បីជួយសម្រួលដល់លទ្ធភាពនៃការអានរបស់គាត់នៅក្នុងបន្ទប់សវនាការ បន្ទាប់ពីកំណត់បាននូវវិធីសាស្ត្រសមស្របបំផុតក្នុងការធ្វើបែបនេះ។

**តាមសំអាងហេតុដូចបានរៀបរាប់ខាងលើ អង្គជំនុំជម្រះសាលាដំបូង÷**

**បញ្ជាក់ថា** ជនជាប់ចោទ ខៀវ សំផន មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ។

**បង្គាប់** ឱ្យធ្វើតេស្តទៅលើមុខងារបញ្ញាស្មារតីរបស់ជនជាប់ចោទ ខៀវ សំផន យ៉ាងហោចណាស់ម្តង រៀងរាល់ត្រីមាស។

**ចាត់តាំង** អ្នកជំនាញឱ្យរៀបចំតេស្ត ដើម្បីវាយតម្លៃទៅលើមុខងារបញ្ញាស្មារតីរបស់ ខៀវ សំផន និង ធ្វើការជាមួយបុគ្គលិកអង្គភាពពេទ្យ អ.វ.ត.ក ដែលមានគុណវុឌ្ឍិ ដើម្បីអនុវត្តតេស្តទាំងនេះ និង ធ្វើរបាយការណ៍ជូនអង្គជំនុំជម្រះសាលាដំបូង។ និង

**បង្គាប់** ឱ្យអង្គភាពគាំពារសាក្សី និង អ្នកជំនាញ ជួយសម្របសម្រួល និង កំណត់កាលបរិច្ឆេទនៃការធ្វើតេស្តទាំងនេះ ដែលនឹងចាប់ផ្តើមមិនឱ្យហួសពីថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៦។

ភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៦

**ជ. ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**យ៉ា សុខន**

[27] ដីកាបង្គាប់ឱ្យធ្វើតេស្តទៅលើសតិបញ្ញាស្មារតីរបស់ នួន ជា និង ខៀវ សំផន ប្រចាំត្រីមាស ឯកសារ E329/9 ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៥។ ដីកាបង្គាប់ឱ្យធ្វើតេស្តទៅលើសតិបញ្ញាស្មារតីរបស់ នួន ជា និង ខៀវ សំផន ប្រចាំត្រីមាស - សេចក្តីបញ្ជាក់ ឯកសារ E329/9.1 ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥។ ដីកាបង្គាប់ឱ្យកំណត់ពេលវេលានៃការធ្វើតេស្តទៅលើសតិបញ្ញាស្មារតីរបស់ជនជាប់ចោទ ឯកសារ E329/11 ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៥។